**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៨**

# កម្មវិធីជំនួយផ្ទាល់របស់ស្ថានទូតអូស្ត្រាលីបើកទទួលពាក្យស្នើសុំ នៅថ្ងៃទី២១ ខែកញ្ញា

កម្មវិធីជំនួយផ្ទាល់របស់អូស្ត្រាលី (DAP) នឹងបើកទទួលពាក្យស្នើសុំសម្រាប់ឆ្នាំ២០១៨ នៅថ្ងៃសុក្រ ទី២១ ខែកញ្ញា។

ថវិកាជំនួយមានទឹកប្រាក់រហូតដល់៦០.០០០ដុល្លារអូស្ត្រាលីសម្រាប់គម្រោងនីមួយៗ នឹងត្រូវផ្តល់ដល់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នក្នុងស្រុកនិងអន្តរជាតិ ដើម្បីអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ខ្នាតតូចដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងទទួលបាននូវការអភិវឌ្ឍប្រកបដោយនិរន្តភាពនៅក្នុងប្រទេសកម្ពុជា។

ស្ថាប័នឯកជន ក៏អាចដាក់ពាក្យស្នើសុំបានដែរ ប៉ុន្តែត្រូវតែអនុវត្តគម្រោងដែលផ្តល់មូលនិធិដោយកម្មវិធីជំនួយផ្ទាល់ (DAP) ដោយមិនយកប្រាក់កម្រៃ។

ឯកអគ្គរាជទូតអូស្ត្រាលីលោកជំទាវ អេនជេលឡា ខកខឺរ៉េន បានមានប្រសាសន៍ថា៖ «ប្រទេសអូស្ត្រាលីមានភាពរីករាយក្នុងការបន្តការគាំទ្រដល់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីជំនួយផ្ទាល់នេះ»។

លោកជំទាវបានបន្តទៀតថា៖ «មូលនិធិនេះ នឹងជួយគាំទ្រគម្រោងអភិវឌ្ឍន៍នានាដើម្បីជួយប្រទេសកម្ពុជាឲ្យកាន់តែមានភាពរឹងមាំ និងនាំមកនូវស្ថេរភាព និងភាពរីកចម្រើនក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិករបស់យើង»។

កម្មវិធីជំនួយផ្ទាល់ គឺជាកម្មវិធីមូលនិធិខ្នាតតូចដែលមានការប្រកួតប្រជែង។ ពាក្យស្នើសុំត្រូវតែឆ្លើយតបទៅនឹងតម្រូវការលំអិតនៅក្នុងគោលការណ៍ណែនាំរបស់កម្មវិធីជំនួយផ្ទាល់ ដែលមាននៅក្នុងវេបសាយរបស់ស្ថានទូតអូស្ត្រាលី៖https://cambodia.embassy.gov.au/penh/cooperation.html

កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំសង្ខេប (Expressions of Interests) គឺថ្ងៃទី០៥ តុលា ២០១៨ ។ ប្រសិនបើអ្នកមានសំណួរផ្សេងៗ អំពីដំណើរការនៃការដាក់ពាក្យ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ dap.phnompenh@dfat.gov.au

សម្រាប់ព័ត៌មានផ្សេងៗសូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au